# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Dec-2012, 13:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## សំណើសុំឲ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចបដិសេធការកោះហៅសាក្សីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឲ្យកែប្រែបែបបទក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

---

| ដាក់ដោយ៖ | ផ្ញើជូន៖ |
|---|---|
| **សហមេធាវីការពារក្តីលោក ខៀវ សំផន** | **អង្គជំនុំជម្រះសាលាដំបូង** |
| លោក គង់ សំអុន | ចៅក្រម និល ណុន |
| លោកស្រី Anta GUISSÉ | ចៅក្រម Silvia CARTWRIGHT |
| លោក Arthur VERCKEN | ចៅក្រម យូរ ឧត្តរា |
| លោក Jacques VERGES | ចៅក្រម Jean-Marc LAVERGNE |
| **ជំនួយការ៖** | ចៅក្រម យ៉ា សុខន |
| លោកស្រី សេង សុជាតា | **សហព្រះរាជអាជ្ញា៖** |
| កញ្ញា Marie CAPOTORTO | លោកស្រី ជា លាង |

| | |
|---|---|
| កញ្ញា Shéhérazade BOUARFA | លោក Andrew CAYLEY |
| កញ្ញា Mathilde CHIFFERT | **មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| កញ្ញា អ៊ុំច ស្រីផាត | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| កញ្ញា ជុំន សុធារី | |
| លោក Pierre TOUCHE | |

## គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មានបំណងយោងទៅសវនាការកាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដែលនៅអំឡុងពេលនោះ មានការរំលោភបំពានជាច្រើនលើសិទ្ធិរបស់ក្រុមមេធាវីការពារក្តី ហើយដែលការរំលោភបែបនេះបានស្តែងឲ្យឃើញពីកំហុសមួយបន្ថែមទៀតនៅក្នុងវិធីស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនាពេលបច្ចុប្បន្ន ហើយដែលកំហុសនេះគប្បីត្រូវមានការកែតម្រូវ[1]។ ក្រុមមេធាវីការពារក្តីសូមស្នើសុំឲ្យមានការពិនិត្យឡើងវិញផងដែរនូវសេចក្តីសម្រេចរបស់លោកប្រធានអង្គជំនុំជម្រះ ដែលបានបដិសេធធ្វើការកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខកូដ TCCP-187។

២. បន្ទាប់ពីបានបញ្ចប់ការផ្តល់សក្ខីកម្មនៅក្នុងសវនាការកាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ រួចមក ដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 ថៅ នី បានស្នើសុំចោទសំនួរទៅកាន់ លោក ខៀវ សំផន នៅពេលដែលលោកត្រូវបានអនុញ្ញាតឲ្យធ្វើការថ្លែងអំពីទុក្ខវេទនារបស់ខ្លួន។ ភ្លាមៗនោះ សហមេធាវីការពារក្តីអន្តរជាតិរបស់លោក ខៀវ សំផន បានធ្វើការកត់សម្គាល់ថា ការថ្លាថ្លែងអំពីទុក្ខវេទនាមិនមែនជាឱកាសសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការវាយប្រហារទៅលើជនជាប់ចោទឡើយ ហើយមេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការរំលឹកអំពីនីតិវិធីជាធរមាន។ ជាមួយគ្នានោះដែរ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលគាំទ្រដោយសហព្រះរាជអាជ្ញា បានធ្វើការបញ្ជាក់ថា ពុំមានវិធានណាមួយនៃវិធានផ្ទៃក្នុងធ្វើការហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យចោទសំនួរ ឬក៏និយាយទៅកាន់ជនជាប់ចោទ នៅក្នុងពេលដែលខ្លួនកំពុងធ្វើសេចក្តីថ្លែងអំពីទុក្ខវេទនានោះឡើយ[2]។

៣. ក្នុងស្ថានភាពដូចនេះ លោកប្រធានអង្គជំនុំជម្រះបានសួរទៅកាន់ លោក ខៀវ សំផន ថាតើលោក ខៀវ សំផន មានបំណងអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏លោកមានបំណងឆ្លើយទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ លោក ខៀវ សំផន បានរំលឹកអំពីជំហារ

---

[1] មេធាវីការពារក្តីលោក ខៀវ សំផន រំលឹកឡើងវិញនៅត្រង់នេះ អំពី "ចម្លើយតប[របស់ខ្លួន]ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីកំណត់វិសាលភាពនៃការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ" ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២១០១២ ឯកសារ E240/1។

[2] សេចក្តីព្រាងប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៧៦ ដល់ ៧៨។

របស់លោក ដោយលោកបាននិយាយថាខ្លួនមិនមានបំណងក្នុងការឆ្លើយទៅនឹងសំណួរទាំងនោះទេ[3]។ នៅពេលដំបូង លោកប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា លោក ខៀវ សំផន "*បានបង្ហាញយ៉ាងច្បាស់ពីជំហររបស់លោក និងបានធ្វើការរំលឹកអំពីជំហរនេះសាជាថ្មី*" ដូច្នេះលោកប្រធានក៏បានបដិសេធសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ បន្តិចក្រោយមក បន្ទាប់ពីបានធ្វើការពិភាក្សាជាមួយចៅក្រមផ្សេងៗទៀតរួចមក លោកប្រធានអង្គជំនុំជម្រះបានប្រកាន់យកជំហររបស់ខ្លួនឯងវិញ ដោយបានអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីអាចចោទសំនួរតាមរយៈអង្គជំនុំជម្រះវិញ[4]។ លោកប្រធានមិនបានផ្ដល់នូវការពន្យល់ណាមួយពាក់ព័ន្ធនឹងការផ្លាស់ប្ដូរយ៉ាងលឿននូវជំហររបស់ខ្លួននេះឡើយ។ ការប្រែក្រឡាស់បែបនេះស្ដែងឲ្យឃើញពីកង្វះខាតនូវភាពច្បាស់លាស់ក្នុងនីតិវិធីជាធរមាននៅចំពោះមុខអង្គជំនុំជម្រះ និងពីភាពចាំបាច់ក្នុងការក្នុងការបញ្ជាក់ឡើងវិញឲ្យបានច្បាស់លាស់ពីនីតិវិធី សំដៅគោរពដល់សិទ្ធិរបស់ក្រុមមេធាវីការពារក្ដី។ ការបញ្ជាក់ឡើងវិញនេះពិតជាមានសារៈសំខាន់ណាស់ ខណៈដែលនីតិវិធីប្រកាន់យកដោយអង្គជំនុំជម្រះនៅក្នុងអំឡុងពេលសវនាការបានរំលោភជាច្រើនដងរួចមកហើយដល់សិទ្ធិរបស់ លោក ខៀវ សំផន។

## I. ការរំលោភសិទ្ធិរបស់ លោក ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌

៤. មេធាវីការពារក្ដីបានរំលឹកថាដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចចោទសួរដោយផ្ទាល់ទៅកាន់ជនជាប់ចោទបានឡើយក្នុងអំឡុងពេលសវនាការ។ វិធាន ៩០ នៃវិធានផ្ទៃក្នុង បានចែងថា លើកលែងតែការសាកសួររបស់សហព្រះរាជអាជ្ញា និងមេធាវី "*រាល់សំណួរទាំងអស់ត្រូវធ្វើតាមរយៈប្រធានអង្គជំនុំជម្រះ និងតាមលំដាប់លំដោយដែលបានកំណត់ដោយប្រធាន*"។ ប៉ុន្តែ ការអនុវត្តបែបនេះអាចជាមធ្យោបាយមួយធ្វើឲ្យជនជាប់ចោទមិនអាចអនុវត្តនូវសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ជាក់ស្ដែងដូចជាករណីដែលបានកើតឡើងនៅក្នុងដំណើរការសវនាការកាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ជាដើម។

---

[3] យោងដូចខាងលើ ទំព័រ ៧៨-៧៩។

[4] យោងដូចខាងលើ ទំព័រ ៧៩ បន្ទាត់ ១៥ ដល់ ២៥។

### ក. ពាក់ព័ន្ធនឹងការរំលោភសិទ្ធិទទួលបានការតំណាងដោយប្រសិទ្ធិភាព

៥. សិទ្ធិក្នុងការទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន មានចែងនៅក្នុងវិធានផ្ទៃក្នុង និងនៅក្នុងគ្រប់លិខិតុបករណ៍អន្តរជាតិទាំងអស់ពាក់ព័ន្ធនឹងការការពារសិទ្ធិមនុស្ស ។ ផ្ទុយទៅវិញ សិទ្ធិមួយនេះដែលជាធាតុផ្សំជាសារវន្តនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ ត្រូវបានរំលោភបំពាននៅក្នុងសវនាការកាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។

៦. ជាក់ស្ដែង នៅក្នុងសវនាការថ្ងៃនោះ បន្ទាប់ពីបានអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចោទសំនួររួចមក លោកប្រធានអង្គជំនុំជម្រះបានសួរទៅលោក ខៀវ សំផន សាជាថ្មីថា តើលោក ខៀវ សំផន មានបំណងឆ្លើយទៅនឹងសំនួរដែរឬទេ[5]។ សហមេធាវីការពារក្ដីលោក ខៀវ សំផន ក៏បានក្រោកឈរឡើងដើម្បីនិយាយ។ ប៉ុន្តែ លោកប្រធានអង្គជំនុំជម្រះបានបដិសេធមិនបើកមីក្រូឲ្យដំណើរការ ដោយបាននិយាយថា "*យើងសួរលោក ខៀវ សំផន។ លោកស្រីមេធាវី យើងសួរមេធាវី -- ខៀវ សំផន បើគាត់មិនឆ្លើយទេ ឲ្យគាត់ឆ្លើយថាគាត់មិនឆ្លើយតបទេ។ បើគាត់ឆ្លើយ សូមអញ្ជើញឆ្លើយ*"[6]។ ដោយមានការទទូចចង់និយាយរបស់មេធាវីការពារក្ដីលោក ខៀវ សំផន លោកប្រធានអង្គជំនុំជម្រះបានបិទមីក្រូ និងបានឆ្លើយថា "*យើងសួរទៅលោក ខៀវ សំផន។ លោកស្រីមេធាវីអង្គុយចុះ...*"។ ព្រឹត្តិការណ៍នេះបានបង្កើតឲ្យមាននូវឈុតឆាកដ៏អាក្រក់មួយគួរឲ្យអស់សំណើច ដែលលោក ខៀវ សំផន មិនទាំងបានពិភាក្សាជាមួយមេធាវីរបស់ខ្លួនជាមុនផង បានស្វែងរកការណែនាំផ្លូវច្បាប់ពីប្រធានអង្គជំនុំជម្រះ៖ "*សូមគោរពលោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរបញ្ជាក់ តើការឆ្លើយតបរបស់ខ្ញុំនៅពេលនេះចំពោះតែសំណួរមួយនេះ វាប៉ះពាល់ដល់ការរក្សាសិទ្ធិនៅស្ងៀមរបស់ខ្ញុំទេ? បើមិនប៉ះពាល់ទេ ខ្ញុំឆ្លើយឥឡូវហ្នឹងបាន*"[7]។ នៅពេលនោះ លោកប្រធានអង្គជំនុំជម្រះមាននាទីជាអ្នកផ្ដល់ការណែនាំ ដោយផ្ដល់នូវចម្លើយមួយដែលការបកប្រែជាភាសាបារាំងមិនសូវជាយល់ច្បាស់ ដោយលោកប្រធានបានបញ្ជាក់ថា៖ "*នេះជាការសម្រេចចិត្តរបស់លោក ពីព្រោះលោកក៏មិនបានសម្រេចចិត្តដាច់ណាត់ថា លោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ពេញដំណើរការនីតិវិធីសវនាការរឿងក្ដី ០០២ នេះ*

[5] យោងដូចខាងលើ ទំព័រ ៨០ បន្ទាត់ ១៩។

[6] យោងដូចខាងលើ ទំព័រ ៨០ បន្ទាត់ ២០-២១។

[7] យោងដូចខាងលើ ទំព័រ៨១ បន្ទាត់ ១១-១៣។

*ដែរ។ លោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបមានល័ក្ខខ័ណ្ឌ។ ដូច្នេះ អ្វីទាំងអស់នេះគឺសម្រេចចិត្តដោយសារលោកខ្លួន។ លោកឆ្លើយ គឺអាចឆ្លើយនឹងសំណួរនេះ។ បើលោកថាមិនឆ្លើយទេ គឺលោកថា រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ នេះជាវិធីក្នុងការឆ្លើយ។ ការសម្រេចចិត្តនៅលើលោកផ្ទាល់ខ្លួន*"[8]។ មេធាវីការពារក្ដីបានព្យាយាមជាលើកចុងក្រោយក្នុងការបញ្ចេញមតិ។ ប៉ុន្ដែ លោកប្រធានអង្គជំនុំជម្រះបានបង្គាប់សាជាថ្មីឱ្យមេធាវី "*អង្គុយចុះ*"[9]។ លោក ខៀវ សំផន ដែលកំពុងតែមានការស្រពេចស្រពិល បានសម្រេចជម្រាបលោកប្រធានអង្គជំនុំជម្រះថា៖ "*បាទ សូមទោសលោកប្រធាន ខ្ញុំបានប្រគល់សិទ្ធិឱ្យមេធាវីខ្ញុំ តំណាងឱ្យខ្ញុំ*"[10]។

៧. លោក ខៀវ សំផន ត្រូវបានតំណាងដោយមេធាវីដែលខ្លួនគាត់ផ្ទាល់ជាអ្នកជ្រើសរើស ហើយគាត់មានសិទ្ធិពិភាក្សាជាមួយមេធាវីរបស់គាត់តាមដែលគាត់ត្រូវការ។ វិធានផ្ទៃក្នុងក៏មានចែងអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន។ សិទ្ធិនេះត្រូវតែមានសុពលភាព មិនមែនមានត្រឹមតែជាទ្រឹស្ដីនោះទេ។ ដូច្នេះជាក់ស្ដែង លោក ខៀវ សំផន ត្រូវតែទទួលបានសិទ្ធិក្នុងការពិគ្រោះជាមួយមេធាវីរបស់ខ្លួន។ ការបំបិទមាត់របស់ក្រុមមេធាវីការពារក្ដី ដោយការកាត់ផ្ដាច់មីក្រូនៅពេលដែលមេធាវីមានបំណងសម្ដែងអំពីជំហរកូនក្ដីរបស់ខ្លួន ឬស្នើសុំពិភាក្សាជាមួយកូនក្ដី គឺជាការអនុវត្តដែលមិនអាចទទួលយកបាន និងមិនគួរឱ្យកើតមានឡើងឡើយ។ ក្រុមមេធាវីការពារក្ដីមានសិទ្ធិក្នុងការបញ្ចេញមតិ ហើយ លោក ខៀវ សំផន ក៏មានសេរីភាពផងដែរក្នុងការនិយាយដោយផ្ទាល់ ឬក៏តាមរយៈមេធាវីដែលជាអ្នកតំណាងផលប្រយោជន៍ឱ្យគាត់។ វិធានផ្ទៃក្នុងតម្រូវឱ្យប្រធានអង្គជំនុំជម្រះ "*ធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តទៅបានដោយសេរី*"[11]។

---

[8] យោងដូចខាងលើ ទំព័រ ៨១ បន្ទាត់ ១៥-២០។

[9] យោងដូចខាងលើ ទំព័រ ៨២ បន្ទាត់ ១។

[10] យោងដូចខាងលើ ទំព័រ ៨២ បន្ទាត់ ១៣។

[11] វិធាន ៨៥ ១) នៃវិធានផ្ទៃក្នុង។

## ខ. ពាក់ព័ន្ធនឹងការរំលោភសិទ្ធិរបស់ លោក ខៀវ សំផន ក្នុងការសួរសាក្សី

៨. លោក ខៀវ សំផន យល់យ៉ាងច្បាស់ពីភាពខុសគ្នារវាងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងល័ក្ខខ័ណ្ឌដូចគ្នាជាមួយនឹងសាក្សី ហើយសក្ខីកម្មរបស់ពួកគេអាចផ្ទុកនូវភ័ស្តុតាងដាក់បន្ទុក។ នៅក្នុងអំឡុងពេលចោទសួរដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណី លោក ចៅ នី ពុំបានធ្វើការយោងណាមួយដល់រូប លោក ខៀវ សំផន ឡើយ។ ដូច្នេះ ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន ពុំមានសំណួរសម្រាប់ចោទសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះឡើយ។

៩. គឺនៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវធ្វើសេចក្ដីថ្លែងអំពីទុក្ខសោករបស់ខ្លួនទៅហើយទេ ដែលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានធ្វើការអះអាងដោយយោងទៅតាមសំដីរបស់អតីតអ្នកបើកបរម្នាក់កាលពីឆ្នាំ ១៩៧៩ ថា នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពូរបស់ខ្លួនម្នាក់ទំនងជាបានទទួលលិខិតឆ្លើយឆ្លងពី លោក ខៀវ សំផន ដែលបានជំរុញឲ្យពូរបស់លោកចូលមកក្នុងទីក្រុងភ្នំពេញវិញ។ ហេតុដូចនេះហើយបានជាដើមបណ្ដឹងរដ្ឋប្បវេណីបានសុំឲ្យ លោក ខៀវ សំផន ប្រាប់អំពីល័ក្ខខ័ណ្ឌនៃការស្លាប់របស់ពូខ្លួន ព្រោះគាត់បានភ្ជាប់ការបាត់ខ្លួនរបស់ពូគាត់ ទៅនឹងលិខិតដែលត្រូវបានចោទប្រកាន់[12]។

១០. សេចក្ដីថ្លែងការណ៍ប្រភេទនេះពាក់ព័ន្ធដោយផ្ទាល់ដល់សកម្មភាព និងការប្រព្រឹត្តបែបសន្មតរបស់ លោក ខៀវ សំផន។ ការណ៍ដែលដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញជាលើកដំបូងនូវអង្គហេតុបែបនេះ បានធ្វើឲ្យក្រុមមេធាវីការពារក្ដីមិនអាចគិតទុកជាមុនបាននូវសេចក្ដីថ្លែងការណ៍ និង សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងពេលសវនាការ។ ដោយបានទទួលយកសំណួរទាំងស្រុងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងដោយមិនបានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្ដីអាចបញ្ចេញមតិបាន លោកប្រធានអង្គជំនុំជម្រះមិនបានអនុញ្ញាតឲ្យមានការពិភាក្សាដេញដោលឡើយ។

១១. គឺនៅក្រោយពេលការចាកចេញរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទៅហើយទេ ដែលលោកប្រធានអង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការកត់សម្គាល់ទៅលើសក្ខីកម្មរបស់

---

[12] សេចក្ដីព្រាងប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៨០ បន្ទាត់ ១-១៧។

ដើមបណ្តឹងរដ្ឋប្បវេណី ដោយភាគីត្រូវប្រាប់អង្គជំនុំជម្រះថាតើក្នុងចំណោមចម្លើយដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី មានចម្លើយណាខ្លះដែលស្ថិតនៅក្រៅក្របខ័ណ្ឌនៃសំណុំរឿង០០២/០១[13]។ នៅពេលបញ្ចប់ មេធាវីការពារក្តីអន្តរជាតិរបស់ លោក ខៀវ សំផន ដែលទទួលបានការអនុញ្ញាតឲ្យនិយាយ បានប្រឆាំងយ៉ាងដាច់អហំការចំពោះនីតិវិធីដែលអង្គជំនុំជម្រះបានអនុវត្ត ក្នុងការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីនិយាយលើសពីការថ្លែងសេចក្តីទុក្ខសោករបស់ខ្លួន ដោយដើមបណ្តឹងរដ្ឋប្បវេណីបាននាំមកនូវ "ភ័ស្តុតាងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ ហើយដែលសេចក្តីថ្លែងការណ៍នេះមិនត្រឹមតែស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ នោះទេ ប៉ុន្តែវាបានបង្កឲ្យមានបញ្ហាដល់សិទ្ធិរបស់ក្រុមមេធាវីការពារក្តី"[14]។ ក្រុមមេធាវីការពារក្តីបានគូសបញ្ជាក់ថា ដោយសារតែការថ្លែងទុក្ខសោកត្រូវបានធ្វើឡើងបន្ទាប់ពីការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ក្រុមមេធាវីការពារក្តីក៏លែងមានសិទ្ធិចោទសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណីទៀត ហេតុដូច្នេះខ្លួនត្រូវបានបំបិទសិទ្ធិក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងភ័ស្តុតាងថ្មីៗ[15]។

១២. ក្រោយពីមានការពិភាក្សារវាងចៅក្រមរួចមក លោកចៅក្រម LAVERGNE បានទទួលសិទ្ធិក្នុងការនិយាយដើម្បីធ្វើការបញ្ជាក់ពីជំហាររបស់អង្គជំនុំជម្រះ ដោយលោកចៅក្រមបានបញ្ជាក់ថា ក្រុមមេធាវីការពារក្តីមិនអាចសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការថ្លែងសេចក្តីទុក្ខសោករបស់ខ្លួន[16]។ ភ្លាមៗនោះ មេធាវីរបស់លោក ខៀវ សំផន បានស្នើសុំឲ្យទទួលស្គាល់នូវសិទ្ធិមួយនេះ[17] ប៉ុន្តែខ្លួនសូមជំទាស់ទៅនឹងការបដិសេធរបស់លោកប្រធានអង្គជំនុំជម្រះដែលបានលើកមូលហេតុថា "*អង្គជំនុំជម្រះបានឲ្យដើមបណ្តឹងរដ្ឋប្បវេណីវិលត្រលប់ទៅលំនៅដ្ឋានរបស់គាត់វិញហើយ ហើយជនជាប់ចោទបានបង្ហាញជំហរច្បាស់លាស់រក្សាសិទ្ធិនៅ*

[13] យោងដូចខាងលើ ទំព័រ ៨៤ បន្ទាត់ ១០-១៤។

[14] យោងដូចខាងលើ ទំព័រ ៨៤ បន្ទាប់ ១៩-២៤ និងទំព័រ ៨៥ បន្ទាត់ ១។

[15] យោងដូចខាងលើ ទំព័រ ៨៥-៨៦។

[16] យោងដូចខាងលើ ទំព័រ ៨៧ បន្ទាត់ ៩-១៣ និងបន្ទាត់ ២៤-២៥។

[17] យោងដូចខាងលើ ទំព័រ ៨៨ បន្ទាត់ ២-៤។

*ស្ងៀមមិនឆ្លើយតបរួចហើយ*'[18]។

១៣. កម្មវត្ថុនៃការពិភាក្សាមិនមែនពាក់ព័ន្ធទៅនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទនោះទេ ប៉ុន្តែគឺវាស្ថិតនៅលើលទ្ធភាពសម្រាប់ជនជាប់ចោទក្នុងការសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចោទប្រកាន់មកលើខ្លួន។ ក្នុងនាមជាមេធាវីរបស់លោក ខៀវ សំផន មេធាវី GUISSE បានស្នើសុំការអនុញ្ញាតសួរដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ថ្មីៗពាក់ព័ន្ធនឹងការប្រព្រឹត្តបែបសន្ធូតរបស់លោក ខៀវ សំផន។ ក្រុមមេធាវីការពារក្តីគ្រាន់តែសុំអនុវត្តនូវសិទ្ធិជាមូលដ្ឋានមួយរបស់ខ្លួនតែប៉ុណ្ណោះ។

១៤. លោក ខៀវ សំផន សូមរំលឹកថាគោលការណ៍ជាធរមាននៅ អ.វ.ត.ក គឺការបង្ហាញខ្លួនសាក្សីនៅសវនាការ ដើម្បីធ្វើការពិភាក្សាតទល់គ្នា[19]។ ការបដិសេធសិទ្ធិបញ្ចេញមតិរបស់ក្រុមមេធាវីការពារក្តី បន្ទាប់ពីការថ្លែងរបស់សាក្សី ឬរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺធ្វើឲ្យបញ្ញត្តមួយនេះគ្មានន័យ។

១៥. ការអនុវត្តធ្វើឡើងក្នុងសំណុំរឿង ០០២ ដែលអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការថ្លែងជាចុងក្រោយពីទុក្ខវេទនា និងព្យសនកម្មរបស់ពួកគេ គឺជាការងាកឆ្ងាយមួយប្រកបដោយភាពគ្រោះថ្នាក់។ ទម្រង់នៃការអនុវត្តនាពេលបច្ចុប្បន្ននេះ គឺផ្ទុយទៅនឹងនីតិវិធីតទល់គ្នា។ ជាពិសេសទៅទៀតនោះ ការអនុវត្តបែបនេះប្រឆាំងទៅនឹងសិទ្ធិរបស់ក្រុមមេធាវីការពារក្តី ក្នុងការនិយាយចុងក្រោយ និងឆ្លើយតបទៅនឹងការចោទប្រកាន់ប្រឆាំងជនជាប់ចោទ។ ការអធិប្បាយរបស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីគាត់បានចាកចេញពីសាលសវនាការហើយនោះ ពុំបានឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌតម្រូវនៃសិទ្ធិទាំងអស់នេះឡើយ។

១៦. ដូច្នេះ លោក ខៀវ សំផន សូមស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិនិត្យឡើងវិញលើសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួន ដែលបានបដិសេធកោះហៅ លោក ចៅ នី មកម្តងទៀតដើម្បីធ្វើការសាកសួរពាក់ព័ន្ធនឹងធាតុផ្សំថ្មីៗ។ វាមានការចាំបាច់ណាស់ក្នុងការគូសបញ្ជាក់ពី

---

[18] យោងដូចខាងលើ ទំព័រ ៨៨ បន្ទាត់ ៩-១១។

[19] វិធាន ៨៤ ១) នៃវិធានផ្ទៃក្នុង។

វិធាន ៨៧ ២) នៃវិធានផ្ទៃក្នុង ដែលចែងថា "*សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការពិភាក្សាដេញដោល*"។ ដោយពុំមានសេចក្ដីសម្រេចជាវិជ្ជមានណាមួយរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការកោះហៅ លោក ថៅ នី មកសាជាថ្មីនោះ លោក ខៀវ សំផន សូមស្នើអង្គជំនុំជម្រះបញ្ជាក់ឲ្យបានច្បាស់ថា ដោយយោងទៅតាមវិធាន ៨៧ ២) នៃវិធានផ្ទៃក្នុង សេចក្ដីថ្លែងការណ៍របស់លោក ថៅ នី ទាក់ទងនឹងទុក្ខវេទនារបស់គាត់ នឹងមិនអាចទទួលយកធ្វើជាភស្តុតាងបានទេ។

១៧. លោក ខៀវ សំផន សូមស្នើអង្គជំនុំជម្រះឲ្យកែប្រែផងដែរនូវការអនុវត្តសព្វថ្ងៃពាក់ព័ន្ធនឹងការថ្លែងសេចក្ដីទុក្ខវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយអង្គជំនុំជម្រះត្រូវប្រកាន់យកការអនុវត្តដែលធ្លាប់ធ្វើនៅក្នុងសំណុំរឿង០០១ ដែលបានអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីអាចបញ្ចេញមតិ នៅក្នុងក្របខ័ណ្ឌគោរពដល់សិទ្ធិរបស់ជនជាប់ចោទ។

## II. នីតិវិធីអនុវត្តនៅក្នុងសំណុំរឿង ០០១

១៨. វិធានផ្ទៃក្នុងពុំបានចែងថាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវធ្វើសេចក្ដីថ្លែងអំពីទុក្ខវេទនា នៅពេលបញ្ចប់ការធ្វើសក្ខីកម្មរបស់ខ្លួននោះទេ។ លទ្ធភាពក្នុងការធ្វើសេចក្ដីថ្លែងការណ៍ដែលត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះបែបនេះ ពុំមានចែងនៅក្នុងច្បាប់ទេ[20]។ រឿងក្ដីបច្ចុប្បន្នជារឿងក្ដីទីពីរដែលកើតមាននៅអ.វ.ត.ក ហើយយើងយល់ឃើញថាវាពិតជាមានភាពចាំបាច់ក្នុងការយោងទៅលើបទពិសោធន៍ទទួលបាននៅក្នុងរឿងក្ដីទីមួយ។

១៩. ជាការពិតណាស់ថា នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបធ្វើការចោទសួរទៅកាន់ជនជាប់ចោទ បន្ថែមទៅលើការថ្លែងអំពីទុក្ខវេទនារបស់គាត់។ ប៉ុន្តែ លក្ខខ័ណ្ឌនៅពេលនោះគឺខុសគ្នាទៅនឹងលក្ខខ័ណ្ឌដែលបានអនុវត្តនៅក្នុងសំណុំរឿង០០២ ហើយលក្ខខ័ណ្ឌទាំងនោះថែមទាំងបានធានាដល់សិទ្ធិរបស់ជនជាប់

[20] អនុស្សរណៈស្ដីពី "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១" ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E141 ទំព័រ ៦-៧។

ចោទ និងបានការពារដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

២០. ក្នុងអំឡុងពេលសវនាការក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០១ កាលពីថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ដើមបណ្តឹងរដ្ឋប្បវេណីបីរូបត្រូវបានស្តាប់ចម្លើយ[21]។ ការសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងតាមលំដាប់នៃនីតិវិធី ដូចតទៅ៖

- ការសួរសំណួរដោយប្រធានអង្គជំនុំជម្រះ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះប្រគល់វេទិកាដល់តំណាងដើមបណ្តឹងរដ្ឋប្បវេណី ឲ្យណែនាំខ្លួនកូនក្តីឲ្យបានឆាប់រហ័ស និងប្រាប់ពីមូលហេតុដែលកូនក្តីរបស់ខ្លួនសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាសំណើទាមទារសំណងពាក់ព័ន្ធនឹងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ។
- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគោរពតាមការណែនាំនេះ ដោយត្រូវយោងទៅលើឯកសារពាក់ព័ន្ធទាំងអស់ដែលគាំទ្រដល់សំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។
- ប្រធានអង្គជំនុំជម្រះ ប្រគល់វេទិកាឲ្យដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុដែលនាំឲ្យខ្លួនដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង និងពាក់ព័ន្ធទៅដល់អង្គហាតុដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ ក៏ដូចជាផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចថ្លែងអំពីទុក្ខវេទនារបស់ខ្លួនទាក់ទងនឹងអង្គហេតុទាំងនោះ។
- មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឲ្យចោទសំណួរដល់កូនក្តីរបស់ខ្លួន។
- សហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឲ្យសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។
- ចៅក្រមផ្សេងៗទៀត មានសិទ្ធិចោទសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។
- មេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យចោទសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។
- វេទិកាត្រូវបានផ្តល់ទៅឲ្យជនជាប់ចោទ ដើម្បីឲ្យគាត់អាចធ្វើសេចក្តីអធិប្បាយផ្សេងៗ។

---

[21] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច" ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D288/4.65.1។

២១. នៅក្នុងអំឡុងពេលសវនាការនេះ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូបមានបំណងចោទសំណួរទៅកាន់ជនជាប់ចោទ។ សំណួរទាំងឡាយ ត្រូវបានចោទសួរនៅក្នុងអំឡុងពេលនៃការសាកសួរធ្វើឡើងដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺនៅមុនពេលការចោទសួរដោយក្រុមមេធាវីការពារក្ដី។ ការអនុវត្តបែបនេះគឺស្របតាមខ្លឹមសារនៃវិធានផ្ទៃក្នុង ដែលបានចែងថា នៅគ្រប់ករណីទាំងអស់ ជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទត្រូវតែមានសិទ្ធិធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយជានិច្ច។

២២. ម្យ៉ាងវិញទៀត នៅក្នុងអំឡុងពេលសវនាការ លោកប្រធានអង្គជំនុំជម្រះបានសួរទៅកាន់ជនជាប់ចោទ បន្ទាប់ពីជនជាប់ចោទបានឆ្លើយទៅនឹងសំណួរដំបូងៗរបស់ដើមបណ្ដឹងរដ្ឋប្បវេណី៖ "*លោកអាចឆ្លើយនឹងសំណួរនេះបានទេ យើងបញ្ជូនសំណួរនេះទៅលោកដើម្បីលោកអាចឆ្លើយនឹងសំណួរ។ យើងសូមជម្រាបដល់ជនជាប់ចោទថា ក្នុងករណីលោកមិនចង់ឆ្លើយ ក៏លោកមានសិទ្ធិនៅក្នុងការមិនឆ្លើយតបនឹងសំណួរនេះដែរ នេះជាសិទ្ធិរបស់លោក។ មិនមែនយើងតម្រូវថា ដាច់ខាតត្រូវតែឆ្លើយនោះទេ។ សូមអញ្ជើញ ប្រសិនបើលោកអាចឆ្លើយបាននឹងសំណួរនេះ ឬក៏លោកមានបំណងចង់ឆ្លើយ*"[22]។ លោកប្រធានអង្គជំនុំជម្រះធានាការអនុវត្តវិធាន ២១ ១) ឃ) នៃវិធានផ្ទៃក្នុង ដែលបានចែងអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការត្រូវចាត់ទុកថាគ្មានទោស សិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុង<u>គ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី</u>ត្រូវផ្ដល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

## III.សំណើរបស់លោក ខៀវ សំផន

២៣. ក្រុមមេធាវីការពារក្ដីរបស់ លោក ខៀវ សំផន ស្នើអង្គជំនុំជម្រះឲ្យប្រកាន់យកនីតិវិធីដែលបានអនុវត្តនៅក្នុងសំណុំរឿង០០១។ នីតិវិធីនេះគោរពទាំងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសិទ្ធិរបស់ក្រុមមេធាវីការពារក្ដី។ ម្យ៉ាងវិញទៀត វាក៏ជាប្រយោជន៍សម្រាប់

[22] យោងដូចខាងលើ ទំព័រ ៧២ បន្ទាត់ ២០-២៤។

យុត្តិធម៌ផងដែរក្នុងការអនុវត្តបែបបនេះ។ ដោយបានអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុដែលជាកម្មវត្ថុនៃសំណុំរឿង និងត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទដែរនោះ អង្គជំនុំជម្រះនឹងជួយសម្រួលដល់សេចក្តីសម្រេចចុងក្រោយរបស់ខ្លួនក្នុងការសម្រេចផ្តល់ ឬក៏បដិសេធនូវការទទួលស្គាល់បុគ្គលរូបនោះជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបង្ហាញពីព្យសនកម្មរបស់ខ្លួន និងពីទំនាក់ទំនងរវាងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងជនជាប់ចោទ នៅក្នុងក្របខ័ណ្ឌនៃសវនាការបច្ចុប្បន្ន។

២៤. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគោរព ព្រោះថាខ្លួនត្រូវបានអនុញ្ញាតឲ្យថ្លែងអំពីទុក្ខសោករបស់ខ្លួនដែលជាកម្មវត្ថុនៃរឿងក្តី និងអាចស្វែងរកចម្លើយបន្ថែមទៀតពីជនជាប់ចោទ។ ជាមួយគ្នានោះដែរ សិទ្ធិរបស់មេធាវីការពារក្តីក៏ត្រូវបានគោរពផងដែរ ព្រោះថាគឺមានតែអង្គហេតុដែលជាកម្មវត្ថុនៃសំណុំរឿង តែប៉ុណ្ណោះដែលនឹងត្រូវលើកឡើង ហើយសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក៏បានកំណត់ពីព្រំដែននៃការចោទសំណួរដោយភាគីផ្សេងៗទៀតផងដែរ។ ជនជាប់ចោទអាចអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ជាទីបញ្ចប់ គោលការណ៍ដែលសំខាន់នោះគឺថាក្រុមមេធាវីការពារក្តីត្រូវមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ។

២៥. សរុបរួមមក គឺមានតែការអនុវត្តនីតិវិធីបែបនេះទេដែលអាចអនុញ្ញាតឲ្យមានការគោរពដល់សិទ្ធិរបស់ជនជាប់ចោទឲ្យបានពេញលេញ។

**យោងតាមសំអាងហេតុនេះ** លោក ខៀវ សំផន សូមស្នើអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **ធានា**ដល់សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។

**ហេតុដូច្នេះ សូមស្នើឲ្យអង្គជំនុំជម្រះមេត្តា៖**

- **កោះហៅសាជាថ្មី** លោក ចៅ នី ឲ្យចូលខ្លួនមកតុលាការ ដើម្បីអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីអាចសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ពាក់ព័ន្ធនឹងការចោទប្រកាន់ថ្មីៗដែលគាត់បានលើកឡើងនៅពេលធ្វើសេចក្តីថ្លែងអំពីទុក្ខវេទនារបស់គាត់។

– **ប្រកាន់យកឡើងវិញនូវ**នីតិវិធីដែលបានអនុត្តនៅក្នុងសំណុំរឿង០០១ លើផ្នែកពាក់ព័ន្ធនឹងការសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណី។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ភ្នំពេញ<br><br>ភ្នំពេញ<br><br>ប៉ារីស<br><br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |